ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ:.....៥៤៣...... សរណន.កសក

# សារាចរណែនាំ
# ស្តីពី
# វិធានការជំរុញការស្តារឡើងវិញការខូចខាតដោយគ្រោះទឹកជំនន់
# រដូវវស្សា ឆ្នាំ ២០១១

នៅរដូវវស្សាឆ្នាំ២០១១នេះ ដោយទទួលបានអំណោយផលទឹកភ្លៀងតាំងពីដើមរដូវ និងដោយមានការខិតខំប្រឹងប្រែងរបស់បងប្អូនកសិករ រួមជាមួយអាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងដោយមានការឧបត្ថម្ភគាំទ្រតាមគ្រប់មធ្យោបាយពីរាជរដ្ឋាភិបាលនោះ ការងារបង្កបង្កើនផលស្រូវមានសន្ទុះលឿនគួរជាទីមោទនៈ ដែលគិតត្រឹមថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១ នេះ យើងសម្រេចស្ទួង ព្រោះបានចំនួន ២.៤៤៣.២៦១ ហិកតា ស្មើនឹង ១០៤,៨៦% នៃផែនការ ២.៣៣០.០៨០ ហិកតា លើសឆ្នាំមុនចំនួន ១៣៨.៤៥២ ហិកតា បើប្រៀបធៀបរយៈពេលដូចគ្នា។

ទន្ទឹមនឹងលទ្ធផលដ៏គួរសង្ឃឹមខាងលើ ដំណាំស្រូវនៅតាមបណ្តាខេត្តមួយចំនួន ត្រូវទទួលរងនូវគ្រោះទឹកជំនន់ជាបន្តបន្ទាប់ ហើយថ្មីៗនេះទៀត ក៏ត្រូវទទួលរងនូវបាតុភូតគ្រោះធម្មជាតិបង្កដោយទឹកជំនន់ទន្លេមេគង្គ និងទឹកជំនន់ទឹកភ្លៀងពីប៉ែកខាងលើ ដែលគិតត្រឹមរសៀលថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១១ បានបង្កការប៉ះពាល់លើផ្ទៃដីសន្ទូង និងស្រូវពង្រោះចំនួន ១៣២.៦៥១ ហិកតា ក្នុងនោះ បណ្តាលឱ្យមានការខូចខាតប្រមាណជា ២៧.៨៨៣ ហិកតាហើយ។

យោងតាមសេចក្តីប្រកាសជូនដំណឹងស្តីពីការឆ្លើយតបគ្រោះអាសន្នទឹកជំនន់ឆ្នាំ២០១១ របស់គណៈកម្មការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១ បានឱ្យដឹងថា ទឹកទន្លេមេគង្គ ទន្លេបាសាក់ និងទន្លេសាប អាចនឹងបន្តកើនឡើងទៀត ដែលជាហេតុបង្កឱ្យមានគ្រោះមហន្តរាយដោយទឹកជំនន់។ ក្នុងគោលបំណងធានាបាននូវសន្តិសុខស្បៀង និងសម្រេចបានតាមគោលនយោបាយជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករបស់រាជរដ្ឋាភិបាល និងជាពិសេសដើម្បីឱ្យលទ្ធផលនៃការងារបង្កបង្កើនផលសម្រេចបានល្អប្រសើរទៅតាមផែនការគ្រោងទុក ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមធ្វើការណែនាំដល់គ្រប់អង្គភាពបច្ចេកទេសក្រោមឱវាទ និងមន្ទីរកសិកម្មរាជធានី ខេត្តទាំងអស់ ត្រូវយកចិត្តទុកដាក់អនុវត្តនូវវិធានការចាំបាច់ និងបន្ទាន់មួយចំនួនដូចខាងក្រោម÷

១. ត្រូវតាមដានជាប្រចាំនូវស្ថានភាពឧតុនិយម និងចាត់មន្ត្រីចុះវាយតម្លៃផលប៉ះពាល់ និងការខូចខាតជាបណ្តើរៗ ដើម្បីទទួលបានតួលេខពិតប្រាកដដោយភ្ជាប់ឱ្យបានទីតាំង និងស្ថានភាពភូមិសាស្ត្រដែលមានលទ្ធភាពអាចស្តារនូវការខូចខាតបាន។

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ : (០២៣) ២១១ ៣៥១ / ២១១ ៣៥២ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
N° 200 Preah Norodom Sangkat Tonle Basak Khan Chamkarmon B V D Phnom Penh, Cambodia Phone . (023) 211 351/211 352, Fax : (855) 23 - 217 320

២. ត្រូវពិនិត្យឡើងវិញនូវសន្និធិស្រូវពូជដែលមានតាមបណ្តាខេត្តនីមួយៗទាំងបរិមាណ និងគុណភាព ហើយត្រូវត្រៀមលក្ខណៈជាស្រេចសម្រាប់កិច្ចអន្តរាគមន៍ស្តារការខូចខាតឡើងវិញនៅពេលខាងមុខតាមស្ថានភាពភូមិសាស្ត្រជាក់ស្តែង។

៣. ត្រូវសិក្សារកទីតាំង និងលទ្ធភាពក្នុងការរៀបចំធ្វើថ្នាលសំណាបរួម ដើម្បីចែកជូនបងប្អូនកសិករធ្វើការដកស្ទូងបានទាន់ពេលវេលានៅពេលទឹកជំនន់ចាប់ផ្តើមស្រក ដោយត្រូវបំផុសកសិករឱ្យស្តារការខូចខាតនេះ ដោយធ្វើស្រែសន្ទូងប្រើពូជស្រូវស្រាល ដែលអាចចំណេញទាំងពេលវេលា ទាំងបរិមាណគ្រាប់ពូជ (ប្រើគ្រាប់ពូជតិច) ទទួលបានទិន្នផលខ្ពស់ និងទាន់រដូវកាលនៅពេលទឹកស្រកទៅវិញ។

៤. ត្រូវពិនិត្យលទ្ធភាព និងត្រៀមលក្ខណៈផ្តល់ពូជដំណាំផ្សេងទៀត (ដូចជា ឪឡឹក ពោត សណ្តែក បន្លែ ដំឡូងជាដើម) ជូនកសិករនៅមូលដ្ឋានណាដែលទទួលរងការខូចខាត ពិសេសតាមភូមិសាស្ត្រដែលមានស្ថានភាពមិនសមស្របនឹងការធ្វើស្រែឡើងវិញ ដើម្បីស្តារការខូចខាត និងធានាបាននូវសុវត្ថិភាពស្បៀងជូនប្រជាពលរដ្ឋ។

៥. ត្រូវជំរុញការណែនាំដល់បងប្អូនកសិករឱ្យបង្កើនការថែទាំដំណាំស្រូវ ដែលមិនរងការខូចខាត ដោយត្រូវកម្ចាត់ស្មៅ បំប៉នជី និងការពារពីការបំផ្លាញដោយកត្តាចង្រៃ និងជំងឺផ្សេងៗ។

៦. នៅពេលទឹកចាប់ផ្តើមស្រក ត្រូវចលនាប្រមូលកម្លាំងប្រជាកសិករឱ្យប្រួបរួមគ្នាធ្វើការជួសជុល ឬលើកភ្លឺឡើងវិញដើម្បីរក្សាទឹកទុកក្នុងស្រែឱ្យបានគត់មត់ ចៀសវាងការកាប់ភ្លឺស្រែដាក់ទ្រូ លប ដែលបណ្តាលឱ្យបាត់បង់ទឹកអស់ពីស្រែ។

ទទួលបាននូវសារាចរណែនាំនេះ គ្រប់អង្គភាពដែលពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងគ្រប់មន្ទីរកសិកម្មរាជធានី ខេត្ត ត្រូវសហការឱ្យបានល្អជាមួយសមត្ថកិច្ចពាក់ព័ន្ធ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ អនុវត្តតាមការណែនាំនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១១

រដ្ឋមន្ត្រី

ជ័ន្ទ សារុន

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី យឹម ឆៃ លី
- គ្រប់សាលារាជធានី-ខេត្ត

  " ដើម្បីជូនជ្រាប "

- អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- គ្រប់មន្ទីរកសិកម្មរាជធានី-ខេត្ត

  "ដើម្បីអនុវត្ត"

- ឯកសារ-កាលប្បវត្តិ